# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៤៨៩ រប-៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើចំពោះ**

**អស់លោកប្រធានតុលាការ និងចៅក្រមទាំងអស់នៃព្រះរាជណាចក្រកម្ពុជា**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការណែនាំអនុវត្តដីកាសម្រេចតាមពាក្យសុំ ។

អស់លោកបានទទួលសារាចរមួយលេខ ៤៧៦ រប-៩៧ ចុះថ្ងៃទី០៨ ឧសភា ១៩៩៧ បដិសេធសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានអនុញ្ញាតឱ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំ ដើម្បីការពារសេចក្តីអន្តរាយដល់ផលប្រយោជន៍ស្របច្បាប់របស់ភាគីដែលប្តឹងសុំ ។

ការបដិសេធសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយមន្ត្រីនៅក្នុងឋានានុក្រមក្រោម ជាកំហុសធ្ងន់ធ្ងរ រំលោភទៅលើគោលការណ៍នៃច្បាប់រដ្ឋបាល ។

ទី១- តាមគោលការណ៍នៃច្បាប់រដ្ឋបាល មន្ត្រីថ្នាក់ក្រោមឥតមានសិទ្ធិទាល់តែសោះសម្រេចព្យួរ ឬលុបសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីពេញសិទ្ធិថ្នាក់លើ ។

ទី២- មន្ត្រីដែលជំនួសរដ្ឋមន្ត្រីជាបណ្តោះអាសន្ន ជាស្តីទី នៅពេលរដ្ឋមន្ត្រីពេញសិទ្ធិអវត្តមានពីក្នុងប្រទេសទទួលសិទ្ធិត្រឹមតែបំពេញការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ឥតមានសិទ្ធិសម្រេចអ្វីឡើយ ។

ទី៣- ការដែលមន្ត្រីស្តីទីបានសម្រេចទុកជាមោឃៈ សេចក្តីសម្រេចរបស់តុលាការជាកំហុសធ្ងន់ធ្ងរមួយទៀត រំលោភទៅលើតុលាការ និងទៅលើរដ្ឋធម្មនុញ្ញ ដែលបែងចែកអំណាចទាំងបីដាច់ពីគ្នា(អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ) ហើយធានាឯករាជ្យនៃអំណាចតុលាការនៅមាត្រា ១០៩ និង មាត្រា ១១១ ។

សម្តេចនាយករដ្ឋមន្ត្រីបានសម្រេចលប់ចោលជាមោឃៈសារាចរលេខ ៤៧៦ រប-៩៧ ខាងលើនេះហើយ តាមសេចក្តីសម្រេចលេខ ១៨ សសរ ចុះថ្ងៃទី១០ ឧសភា ១៩៩៧ ។

ខ្ញុំសូមអស់លោកបន្តអនុវត្តសារាចរលេខ ០៥ រប-៩៧ ចុះថ្ងៃទី១១ មេសា ១៩៩៧ តទៅទៀត ហើយសូមមានសតិអារម្មណ៍ហ្នឹងហ្ន កុំយកចិត្តទុកដាក់លើពាក្យវាយប្រហារដោយអរយុត្តិធម៌ ដែលបម្រើផលប្រយោជន៍គណៈបក្ស មកលើតុលាការយើង ដែលខ្ញុំយល់ថាបានខិតខំបំពេញភារកិច្ចបម្រើប្រជាជនអស់ពីចិត្តពីថ្លើមលើកលែងតែបុគ្គលមួយចំនួនតូចដែលមិនទាន់បានពង្រឹងសីលធម៌ស្អាតស្អំរបស់ខ្លួនតាមការអប់រំណែនាំរបស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមអស់លោកប្តូរផ្តាច់រក្សាសីលធម៌បម្រើប្រជាជនអោយបានកម្រិតខ្ពស់បំផុត ហើយរក្សាកិត្តិយសរបស់អស់លោក និងឥទ្ធិពលរបស់តុលាការឱ្យបានដាច់ខាត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**